# ឯកសារទស្សនទាន

# សិក្ខាសាលាថ្នាក់ជាតិ ស្តីពី
# កាតព្វកិច្ចសារពើពន្ធ និងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ TOI E-Filling"
# សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

**កាលបរិច្ឆេទ៖ ថ្ងៃព្រហស្បតិ៍ ទី២១ ខែធ្នូ ឆ្នាំ ២០២៣**

ម៉ោង៖ ៨.០០ ព្រឹក ដល់ម៉ោង ១២.០០ ថ្ងៃត្រង់

ទីកន្លែង៖ **ភោជនីយដ្ឋាន ទន្លេបាសាក់ ២**

*(អគារ ៥៣៨ មហាវិថីព្រះមុន្នីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ)*

## ១. សាវតារ

ការពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ចំពោះនីតិបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន ដោយរួមបញ្ចូលទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានជះឥទ្ធិពលលើបរិកាសអំណោយផលរបស់សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ក្នុងនោះដែរ ដើម្បីជំរុញឲ្យមានកំណើនចំណូល និងតម្លាភាពក្នុងការបង់ពន្ធក្នុង វិស័យពន្ធដាររបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទំនើបកម្មបច្ចេកវិទ្យាមួយចំនួនដូចជា មានប្រព័ន្ធប្រកាសពន្ធអាជីវកម្មតាមអនឡាញ (E-Filing) និង Desktop Application, ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment), និងប្រព័ន្ធគ្រប់គ្រង និងតាមដានឯកសារ (Document Tracking)។ ការវិវត្តខាងលើនេះ បានក្លាយទៅបញ្ហាប្រឈមមួយដ៏សំខាន់របស់អង្គការសង្គមស៊ីវិលនៅកម្ពុជាជាទូទៅ ជាពិសេស ការខ្វះខាតចំណេះដឹង និងធនធានមនុស្សរបស់ពួកគេក្នុងការធ្វើអនុលោមភាពសារពើពន្ធ។

ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើតក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និង សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ២០១៩ តាមរយៈប្រកាសលេខ ១០១ សហវ ប្រក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។ អគ្គនាយកដ្ឋានពន្ធដារបានសហការជាមួយអង្គការសង្គមស៊ីវិល រៀបចំសិក្ខាសាលាជូនបុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនលើកនៅកម្រិតថ្នាក់ជាតិ និងរាជធានី-ខេត្ត ជាច្រើន ចាប់តាំងពីឆ្នាំ២០១៩ ដើម្បីពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលស្តីពីកាតព្វកិច្ច និងអនុលោមភាពពន្ធដារឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្ត និងការវិវត្តន៍ថ្មីៗនៃក្របខ័ណ្ឌច្បាប់ បទបញ្ញត្តិដែលពាក់ព័ន្ធជាច្រើនទៀតនាប៉ុន្មានឆ្នាំចុងក្រោយនេះផងដែរ។

ថ្មីៗនេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលធ្វើការចុះបញ្ជីដោយស្ម័គ្រចិត្តក្នុងរយៈពេលអន្តរកាលនេះ (២០២៤ - ២០២៨) នឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជាការលើកលែងពិន័យនានា និងបំណុលពន្ធព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀត។ ក្រោយពីបានទទួលដំណឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក្រុមការងារសមាគម និងអង្គការសង្គមស៊ីវិល បានពិភាក្សាអំពីបញ្ហានេះ ប៉ុន្តែក្រុមការងារ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability
GPP
Symbol of Trust
05/10/2018 04/10/2021

យើងខ្ញុំ នៅមិនទាន់យល់ច្បាស់នៅឡើយពីខ្លឹមសារខាងលើ ថាតើមានអានុភាពគ្រប់ដណ្តប់លើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែរ ឬយ៉ាងណា។

ស្របពេលដែលឆ្នាំសារពើពន្ធ ២០២៣ នឹងបញ្ចប់ត្រឹមបំណាច់ខែធ្នូ ខាងមុខនេះ។ ដូច្នេះ ដើម្បីរួមចំណែកធ្វើឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចត្រៀមខ្លួនបានល្អប្រសើរក្នុងការធ្វើអនុលោមភាពស្របតាមច្បាប់ស្តីពីសារពើពន្ធ ព្រមទាំងបទប្បញ្ញត្តិសារពើពន្ធផ្សេងទៀតនោះ គ.ស.ក ស្នើសុំកិច្ចសហប្រតិបត្តិការជាមួយ អគ្គនាយកដ្ឋានពន្ធដារ រៀបចំសិក្ខាសាលាបំប៉នបន្ថែមដល់បុគ្គលិកផ្នែកហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំរបស់បណ្តាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងសមាជិក និងមិនមែនសមាជិកនៃអង្គការគ.ស.ក។ តាមរយៈសិក្ខាសាលានេះ ត្រូវបានរំពឹងទុកថា ទាំងបុគ្គលិកផ្នែកហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នឹងអាចស្រាយបំភ្លឺនូវចំងល់ស្តីពីនីតិវិធីនៃការអនុវត្តកាតព្វកិច្ចខាងលើបានល្អប្រសើរ។

## ២. គោលបំណង

- ដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីការអនុវត្តកាតព្វកិច្ចសារពើពន្ធ និងការប្រកាសពន្ធប្រចាំឆ្នាំសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។
- បង្កើតឱ្យមានកិច្ចសន្ទនារវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយតំណាងអគ្គនាយកដ្ឋានពន្ធដារ និងផ្តល់ឱកាសឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានឱកាសលើកឡើងពីបញ្ហាប្រឈមរបស់ពួកគេក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ។
- ពង្រឹងភាពជាដៃគូរ និងការយោគយល់គ្នារវាងសង្គមស៊ីវិលជាមួយអគ្គនាយកដ្ឋានពន្ធដារ។

## ៣. អ្នកចូលរួម

សិក្ខាកាមដែលរំពឹងថានឹងអញ្ជើញចូលរួមនៅក្នុងសិក្ខាសាលានេះមានចំនួនសរុបប្រមាណ ៣០០ នាក់ ដែលជាតំណាងអង្គការជាតិ និងបរទេសជាសមាជិកនៃអង្គការ គ.ស.ក បណ្តាញសម្របសម្រួលនៃអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត ព្រមទាំងបណ្តាសមាគម អង្គការដៃគូសង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត ។

## ៤. របៀបវារៈពន្យខាង

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ៧:៤៥ – ៨:១៥ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារអង្គការ គ.ស.ក |
| ៨.១៥ – ៨.៣០ | ប្រកាសហេតុ និងគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | ក្រុមការងារអង្គការ គ.ស.ក |
| ៨:៣០ – ០៩:១០ | ការណែនាំនៃកម្មវិធី និងគោលបំណងសិក្ខាសាលា<br><br>សុន្ទរកថាស្វាគមន៍ដោយ **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក | លោកស្រី **ប្រាក់ កែវគន្ធា**<br>អ្នកឯកទេសផ្នែកច្បាប់ អង្គការ គ.ស.ក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
05/10/2018 04/10/2021
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

| | | |
|---|---|---|
| | សុន្ទរកថាបើកកម្មវិធីដោយ **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | |
| ៩:១០ – ៩:៣០ | ថតរូបជុំគ្នា និង សម្រាកពិសារអាហារសំរន់ | ទាំងអស់គ្នា |
| ៩:៣០ - ១០:៣០ | • បទបង្ហាញស្តីពី "**ការអនុវត្តកាតព្វកិច្ចសារពើពន្ធសម្រាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល**"<br>• បទបង្ហាញស្តីពី "**ការចុះបញ្ជីអាជីវកម្មដាច់ដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**"<br>○ លើកលែងពិន័យនានា បំណុលពន្ធ ចំពោះការមិនបំពេញអនុលោមភាព<br>○ ការផ្តល់ការលើកទឹកចិត្តខាងពន្ធដារស្របតាមគោលការណ៍អនុគ្រោះ ៩ ចំណុចតាមអនុសាសន៍ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | មន្ត្រីបច្ចេកទេសនៃអគ្គនាយកដ្ឋានពន្ធដារ<br>(បញ្ជាក់ជូនតាមក្រោយ) |
| ១០:៣០ – ១១:០០ | បទបង្ហាញស្តីពី "**ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ** TOI E-Filing" សម្រាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល | មន្ត្រីបច្ចេកទេសនៃអគ្គនាយកដ្ឋានពន្ធដារ<br>(បញ្ជាក់ជូនតាមក្រោយ) |
| ១១:០០ – ១២:០០ | **វេទិកាសំណួរចម្លើយ**<br>▪ ការអនុវត្តកាតព្វកិច្ចសារពើពន្ធ និង ToI E-Filing សម្រាប់សមាគម និងអង្គការសង្គមស៊ីវិល (វាគ្មិនមន្ត្រីជំនាញពីអគ្គនាយកដ្ឋានពន្ធដារ) | សម្របសម្រួលដោយ លោកស្រី **លុយ ឆារី** ប្រធានកម្មវិធីអង្គការ គ.ស.ក |
| ១២:០០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |

***កំណត់សម្គាល់:** អ្នករៀបចំកម្មវិធីសូមថតរូប វីដេអូ ឬសម្លេងសម្រាប់ការអប់រំផ្សព្វផ្សាយ និងកត់ត្រាកំណត់ហេតុ និង សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈខាងលើតាមការចាំបាច់ ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងអ្នករៀបចំកម្មវិធី ៕



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
05/10/2018 04/10/2021
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត